# កើត

# ចាស់

# ឈឺ

# ស្លាប់

សុចិន្ត បរិហារវនខេត្ត

ព.ស ២៥៦៥ គ.ស ២០២១

# ពាក្យប្រារព្ធ

កុសលចេតនាដែលដឹកនាំឱ្យមានការព្យាយាមខំប្រែសៀវភៅ "**កើត ចាស់ ឈឺ ស្លាប់**" របស់មូលនិធិសិក្សា និងផ្សព្វផ្សាយព្រះពុទ្ធសាសនាពីភាសាថៃ មកជាខេមរភាសា ដោយចំណេះដ៏តិចតួចស្តួចស្តើងនេះ **អាស្រ័យហេតុ៖**

- ដោយដើម្បីជាទីសក្ការៈបូជាចំពោះព្រះរតនត្រ័យផង ។
- ដោយសេចក្តីប្រារព្ធដល់គុណូបការៈនៃមាតាបិតា ព្រមទាំងអតីតកាលផង ។
- ដោយសេចក្តីគោរពដល់គុណូបការៈនៃលោកគ្រូធម្មាចារ្យទាំង២គឺ៖
    - លោកអាចារ្យ **សុចិន្ត បរិហារវនខេត្ត**
    - លោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** ព្រមទាំងអតីតកាលផង ។
- ដោយសេចក្តីប្រារព្ធដល់គុណូបការៈនៃគណៈកម្មការបរិហារមូលនិធិផង ។
- ដោយការមិនធ្លាប់ដែលបានឃើញបានឮសេចក្តីបរិយាយធម៌ណែនាំ អប់រំយ៉ាងល្អិតត្រឹមត្រូវច្បាស់លាស់ក្នុងអត្ថនៃពុទ្ធឱវាទរបស់អាចារ្យ មានដូចយ៉ាងនេះមិនដែលមានផង ។
- ដោយដើម្បីសិក្សា និងបដិបត្តិជាសម្មាទិដ្ឋិ ដឹងច្បាស់រូបធម៌ និងនាមធម៌ ហើយដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទផង ។
- ដោយការតម្កល់ចិត្តរួមចំណែកក្នុងគោលបំណងរបស់មូលនិធិផង ។
- កាលប្រែចប់ហើយ ខ្ញុំបានយកទៅជូនលោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** សុំឱ្យលោកជួយពិនិត្យផ្ទៀងផ្ទាត់ខ្លឹមសារធម៌ លោកក៏បានទទួលពិនិត្យហើយ ឃើញថាត្រឹមត្រូវ ។
- សូមកុសលនេះជួយឧបត្ថម្ភគាំទ្រនូវលោកដ៏មានគុណផង លោកគ្រូអាចារ្យផង យើងខ្ញុំទាំងឡាយផង អ្នកសិក្សារៀនសូត្របដិបត្តិទាំងឡាយផង ឱ្យបានសេចក្តីសុខចម្រើនតទៅ ។

**អ្នកប្រែ៖ រស់ សុផាត**

# អ្នកមានឧបការៈក្នុងការធ្វើសៀវភៅ
# ជាធម្មទាននេះ

មានៈ

- ❖ ព្រះអភិនន្ទនាការ **ភិក្ខុសុមនត្ថេរ ហួន ម៉ុនហាន** ។
- ❖ លោកគ្រូធម្មាចារ្យ **រស់ សុផាត**
- ❖ *លោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ* **ប៊ុត សាវង្ស**
- ❖ លោក **យក់ រិទ្ធិយា**
- ❖ លោក **អាន សេរីវុឌ្ឍ** វាយអត្ថបទ និងត្រួតពិនិត្យឡើងវិញ
- ❖ លោក **ចែម ផាន់ណារិទ្ធ** ត្រួតពិនិត្យឡើងវិញ
- ❖ លោក **ឡុង សំនាង** ត្រួតពិនិត្យ និងបានជូនសៀវភៅចាស់មកក្រុមការងារ ដើម្បីវាយឡើងវិញ ។

# អង្គុត្តរនិកាយ តិកនិបាត
# ទេវទូតវគ្គទី ៤ ព្រហ្មសូត្រ ខ.៤៧០

ម្នាលភិក្ខុទាំងឡាយ ត្រកូលណាដែលបុត្តបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលនោះមានព្រហ្ម ត្រកូលណាដែលបុត្តបូជាមាតាបិតា ត្រកូលនោះមានបុព្វាចារ្យ ត្រកូលណាដែលបុត្តបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលនោះមានអាហុនេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថាព្រហ្មនេះ ជាឈ្មោះរបស់មាតា និងបិតា ពាក្យថាបុព្វាចារ្យនេះ ជាឈ្មោះរបស់មាតា និងបិតា ពាក្យថាអាហុនេយ្យបុគ្គលនេះ ជាឈ្មោះរបស់មាតា និងបិតា សេចក្តីនោះព្រោះហេតុអ្វី ព្រោះមាតាបិតាមានឧបការៈច្រើនណាស់ ទំនុកបម្រុងចិញ្ចឹមបីបាច់រក្សាបង្ហាញលោកនេះដល់បុត្ត ។

មាតាបិតាអ្នកអនុគ្រោះបុត្ត លោកហៅថាព្រហ្មបុព្វាចារ្យ និងអាហុនេយ្យបុគ្គលរបស់បុត្ត ព្រោះហេតុនោះឯង បុត្តដែលជាអ្នកមានបញ្ញាគប្បីគោរព និងធ្វើសក្ការៈដល់មាតាបិតាដោយ បាយ ទឹក នំ ចំណី សំលៀកបំពាក់ ទីដេក គ្រឿងក្រអូប ការងូតទឹកជម្រះកាយ និងការដុសលាងជើងទាំងទ្វេ ព្រោះការទំនុកបម្រុងបីបាច់មាតាបិតានោះ បណ្ឌិតរមែងសរសើរបុត្តនោះ បុត្តនោះលះលោកនេះទៅហើយ រមែងមានកំណើតក្នុងឋានសួគ៌ ។

# អង្គុត្តរនិកាយ បញ្ចកនិបាត
## បុត្តសូត្រ ខ.៣៩

បុត្តដែលជាអ្នកសប្បុរស ជាអ្នកស្ងប់ មានកតញ្ញូកតវេទី កាលរលឹកដល់បុព្វគុណរបស់លោក ទើបចិញ្ចឹមបីបាច់មាតាបិតា ធ្វើកិច្ចការជំនួសលោក ស្ដាប់បង្គាប់នូវឱវាទលោក ចិញ្ចឹមតបស្នងសងព្រះគុណលោក ឱ្យសមដូចដែលលោកជាបុព្វការីទ្រទ្រង់នូវវង្សត្រកូល បុត្តដែលជាអ្នកមានសទ្ធា សម្បូរដោយសីល រមែងជាទីសរសើរទូទៅ ។

# ព្រះសទ្ធម្ម
# កើត ចាស់ ឈឺ ស្លាប់

អ្នកជ្រះថ្លាក្នុងព្រះពុទ្ធជាម្ចាស់ រមែងក្រាបថ្វាយបង្គំបូជាសូត្រធម៌ធ្វើវត្តជាប្រចាំរឿយៗ ហើយក៏ត្រូវស្តាប់ព្រះធម៌ និងពិចារណានូវព្រះធម៌ផងដែរ ស្តាប់ព្រះធម៌កាន់តែច្រើនឡើង ក៏ឃើញព្រះបញ្ញាគុណរបស់ព្រះដ៏មានព្រះភាគកាន់តែច្រើនឡើង ព្រោះព្រះធម៌ដែលព្រះមានព្រះភាគទ្រង់សំដែង ជាសច្ចធម៌ ជាធម៌ដែលមានពិត សឹងមនុស្សគ្រប់គ្នាអាចពិសោធន៍បានទាន់ពេល ដោយមិនចាំបាច់ត្រូវប្រុងប្រៀបរៀបចំរង់ចាំឡើយ ។ ព្រះធម៌ថែរក្សាអ្នកប្រព្រឹត្តនូវធម៌ កុសលគាំទ្រឱ្យផុតទុក្ខភ័យ ។

អ្នកកើតមកក្នុងជាតិនេះ តើគ្រាន់តែដើម្បី ឃើញ ឮ ធុំក្លិន ដឹងរស សម្ផស្ស និងនឹកគិតនូវវត្ថុដែលឃើញ នឹកគិតនូវសម្លេងដែលឮ នឹកគិតនូវរស នឹកគិតនូវសភាវៈដែលប៉ះត្រូវសម្ផស្ស តាំងពីកើតរហូតដល់ស្លាប់តែប៉ុណ្ណោះឬ ?

គួរដឹងថា ចំណែកមួយរបស់ជីវិតជាផលរបស់កម្ម និងមួយចំណែកទៀត ជាការសន្សំកម្ម ដែលនឹងធ្វើឱ្យកើតផលខាងមុខ គួរខំកសាងសន្សំកុសល ព្រោះមិនមានអ្នកណាដឹងបានស្អែកនេះអាចឃ្លាតចាកលោកនេះទៅក៏បាន ។

ចំពោះអ្នកដែលនៅមានជីវិតរស់នៅកុំប្រមាទថា អ្នកដឹងហើយ ឃើញហើយ គួរស្តាប់ព្រះធម៌ដើម្បីត្រិះរិះសាចុះសាឡើងនូវធម៌ដែលអ្នកបានរៀនចេះ ហើយគួរពិចារណានូវធម៌នោះរឿយៗ សាកសួររកហេតុផល រកខុសត្រូវ ពិចារណាដោយខ្លួនឯង ដាស់តឿនខ្លួនឯង ឱ្យយកចិត្តទុកដាក់សិក្សា និងស្តាប់នូវព្រះធម៌រហូតដល់មានបញ្ញាយល់ក្នុងព្រះធម៌នោះ រួចហើយបង្អោននាំយកព្រះធម៌មកប្រព្រឹត្តបដិបត្តិ តាមដោយសេចក្តីគោរព ។

កុសលណាៗដែលកើតពីសៀវភៅនេះ សូមឧទ្ទិសកុសលនោះជាបច្ច័យឱ្យដល់ ម.ល.ទ័យគ្រៀម ស្និទ្ធវង្ស បានអនុមោទនាក្នុងកុសលនោះៗផងចុះ ។

គណៈសិក្សា និងផ្សព្វផ្សាយព្រះពុទ្ធសាសនារួបរួមចាត់ការបោះពុម្ពពាក្យបរិយាយរបស់ **អាចារ្យ សុចិន្ត បរិហារវនខេត្ត** ដើម្បីអនុស្សរណៈក្នុងថ្ងៃព្រះរាជទានភ្លើងសព ម.ល.ទ័យគ្រៀម ស្និទ្ធវង្ស ។

# សន្ទនាធម៌នៅសណ្ឋាគារ ទន្លេគែច ខេត្ត កាញ្ចនបុរី

( ២៦ តុលា ២៥៣០ )

សុចិន្ត បរិហារវនខេត្ត

ទាន់ពេលដែលកើតមកហើយ ក៏ជាផលរបស់កម្មដែលស្រេចតែវិបាកចិត្តប្រភេទណាមួយ ធ្វើកិច្ចបដិសន្ធិ បើបដិសន្ធិចិត្តជាអកុសលវិបាក គឺជាផលរបស់អកុសលកម្ម ក៏កើតក្នុងនរក កើតជាប្រេត កើតជាអសុរកាយ កើតជាឆ្កែ កើតជាខ្លា កើតជាមាន់ ជាដើម បើជាផលរបស់កុសលដ៏ទន់ខ្សោយ ទោះបីកើតជាមនុស្ស អកុសលក៏បៀតបៀនធ្វើឱ្យមានរូបរាងកាយពិការតាំងពីកំណើត ភ្នែកខ្វាក់ ត្រចៀកថ្លង់ជាដើម ។

កាលកើតមកហើយក៏ត្រូវឃើញ ត្រូវឮ ត្រូវធុំក្លិន ត្រូវដឹងរស ត្រូវដឹងសម្ផស្ស និងនឹកគិត ខណៈឃើញជាផលរបស់កម្ម ខណៈឮក៏ជាផលរបស់កម្ម ខណៈធុំក្លិនក៏ជាផលរបស់កម្ម ខណៈដឹងរសឆ្ងាញ់ ឬមិនឆ្ងាញ់ក៏ជាផលរបស់កម្ម ខណៈដឹងសម្ផស្សសភាវៈដែលទន់ រឹង ក្តៅ ត្រជាក់ក៏ជាផលរបស់កម្ម ដែលជ្រើសរើសមិនបាន រូបរាងកាយក៏កើតព្រោះកម្មដែរ។ គ្រប់ភពគ្រប់ជាតិដែលកើតមក ឃើញ ឮ ធុំក្លិន ដឹងរស ដឹងសម្ផស្ស និងនឹកគិតនូវវត្ថុដែលឃើញ នឹកគិតនូវសំឡេងដែលឮ នឹកគិតនូវក្លិន

នឹកគិតនូវរស នឹកគិតនូវសភាវៈដែលប៉ះត្រូវសម្ផស្សតាំងពីកើតរហូតដល់ស្លាប់ គឺគ្រាន់តែប៉ុណ្ណោះឯង ។

គ្រប់ជីវិតប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ទាំងសុខ ទាំងទុក្ខ ទាំងពេញចិត្ត ទាំងថ្នាំងថ្នាក់ចិត្ត កើតឡើងត្រឹមតែ ១ ជួរខណៈនៃចិត្ត ហើយក៏រលត់អស់ទៅ ។ អ្នកដែលមិនមែនជាព្រះអរហន្ត ស្លាប់ហើយត្រូវកើតទៀតប្រាកដ តែថាជាតិបន្ទាប់នោះ នឹងកើតជាអ្វី បើជាផលរបស់អកុសលកម្មក៏កើតជាសត្វតិរច្ឆាន កើតក្នុងនរក កើតជាប្រេត កើតជាអសុរកាយ បើជាផលរបស់កុសលកម្មក៏កើតជា មនុស្ស ឬទេវតា ។

ចំណែកមួយរបស់ជីវិតជាវិបាក គឺផលរបស់កម្ម និងមួយចំណែកទៀតជាការសន្សំកម្មដែលនឹងធ្វើឱ្យកើតផលខាងមុខ ។ ខណៈឃើញ ខណៈឮ ខណៈធុំក្លិន ខណៈដឹងរស ខណៈដឹងសម្ផស្ស ជាផលរបស់កម្ម ប៉ុន្តែខណៈគិតមិនមែនជាផលរបស់កម្មទេ ។ ចិត្តដែលគិតមាន ២ យ៉ាង គឺល្អ និងគិតមិនល្អ ។ បើគិតល្អក៏ជួយសង្គ្រោះអ្នកដទៃ មានមេត្តា ករុណា គិតក្នុងផ្លូវលះបង់អកុសល បើគិតមិនល្អទេក៏គិតតែក្នុងផ្លូវដែលមិនជាប្រយោជន៍ ។ សូម្បីគ្រាន់តែពាក្យនិយាយ ក៏អាចបំផ្លាញអ្នកដទៃបាន ដូច៖ **វេលាដែលស្តាប់រឿងអ្វីមួយរួចមកហើយ មិនបានគិតគួរពិចារណាក៏និយាយបណ្តោយតាម ទៅទាំងដោយមិនដឹងនូវសេចក្តីពិត ពាក្យនិយាយនោះក៏អាចធ្វើឱ្យអ្នកដទៃ កើតទុក្ខក្តៅក្រហាយបាន** ក្នុងខណៈ

នោះក៏ជាអកុសល អកុសលឱ្យទោសតាំងពីផ្ដើមគិតម្ល៉េះ ជនជាអ្នកគិតក្ដៅក្រហាយ ព្រោះអកុសលនោះមុនអ្នកដទៃ ដូច្នោះត្រូវឃើញទោសរបស់គំនិតដែលមិនល្អ ។ ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ប្រៀនប្រដៅថា **លោភៈ** សេចក្ដីប្រកាន់មាំ សេចក្ដីជាប់ស្អិតការពាក់ព័ន្ធគ្រប់យ៉ាងនឹងនាំមកនូវសេចក្ដីទុក្ខ **ទោសៈ**ជាសភាវធម៌ដែលគ្រោតគ្រាត ប្រទូសរ៉ាយបំផ្លិចបំផ្លាញ ។

អកុសលទាំងឡាយនោះកើតឡើង ព្រោះសេចក្ដីមិនដឹង មិនដឹងថាខ្លួនឯងមកពីលោកណា មិនដឹងថាស្លាប់ហើយនឹងទៅណា មួយថ្ងៃៗធ្វើអ្វីព្រោះអ្វីក៏មិនដឹង ដែលទូទាំងលោកកំពុងលំបាកនោះ ព្រោះជា**ទាសៈ**របស់សេចក្ដីដឹងខ្លួន ជាសុខដែលកើតឡើងពេលបានវត្ថុជាទីពេញចិត្ត កាលបើបានវត្ថុជាទីប្រាថ្នាមកហើយ ក៏ស្វែងរកនូវវត្ថុជាទីពេញចិត្តដទៃៗទៀតមិនចេះចប់ ដោយមិនដឹងសេចក្ដីពិតថា រសអាហារឆ្ងាញ់ក៏រលត់អស់ទៅហើយ សំឡេងដ៏ពីរោះប្រាកដមួយភ្លែត ក៏រលត់អស់ទៅហើយ ដោយមិនមាននរណាជាម្ចាស់របស់សភាវៈណាបានឡើយ ។

ព្រោះគ្រប់សភាវៈកើតឡើងព្រោះហេតុបច្ច័យ ហើយរលត់អស់រលីងទៅយ៉ាងរហ័ស រាងកាយដែលរឹងមាំទាំ ក៏អាចឈឺចុកចាប់បាន សូម្បីការឈឺចុកចាប់អស់១ថ្ងៃ ក៏អាចជាសះស្បើយជាធម្មតាបាន គ្រប់យ៉ាងមិនតាំងនៅបាន ។

**ខណៈណាដែលជាផលរបស់កុសល ក៏កុំជាប់ស្អិតខ្លាំង ត្រូវប្រុងប្រៀបមទទួលព្រមនូវអកុសលវិបាក ដោយសេចក្តីមិនញាប់ញ័រវេលានេះដែលមានទុក្ខច្រើនអនេក ក៏ព្រោះសេចក្តីញាប់ញ័រនោះឯង ។**

បើដឹងនូវសេចក្តីពិតថា វត្ថុគ្រប់យ៉ាងជាធម្មតា "ធម៌គឺធម្មតា" កើតក៏ធម្មតា ចាស់ក៏ធម្មតា ឈឺក៏ធម្មតា បានលាភក៏ធម្មតា វិនាសលាភក៏ធម្មតា បានកេរ្តិ៍ឈ្មោះឬបាត់បង់កេរ្តិ៍ឈ្មោះក៏ធម្មតា មានអ្នកណាខ្លះមិនត្រូវនិន្ទាឬថាតែងមានតែមនុស្សគោរពរាប់អានរៀងរាល់វេលា ។ សភាវធម៌ដែលកើតឡើងហើយរលត់ទៅនោះជាទុក្ខ គឺមិនទៀង មិនស្ថិតស្ថេរ ចិត្តកើតឡើង ១ ខណៈ ហើយក៏រលត់ទៅ ចិត្តខណៈបន្ទាប់ក៏កើតឡើងហើយក៏រលត់ទៅ បន្តគ្នាទៅរឿយៗ ខណៈឮសំឡេងមិនមែនខណៈឃើញ បញ្ញាត្រូវដឹងតាមសេចក្តីពិត ទើបនឹងមិនយល់ខុសថាជាតួខ្លួន ។ បើនៅរួមគ្នាទាំងឃើញ ទាំងឮ ក៏ជាយើង ក៏ជាតួខ្លួន ។ សភាវធម៌ដែលកើតរលត់នោះខ្លីជាទីបំផុត រហ័សជាទីបំផុត ជាសភាវធម៌ដែលមានពិតហើយល្អិតណាស់ សឹងអាចពិសោធន៍បាន ប៉ុន្តែត្រូវស្តាប់ឱ្យច្រើន ឱ្យយល់ពិតៗថា "ទុក្ខតាំងពីកើត" ។ ឈឺជាទុក្ខ ការព្រាត់ប្រាស់ចាកវត្ថុដែលស្រឡាញ់ជាទុក្ខ ការប្រសព្វនឹងវត្ថុដែលមិនស្រឡាញ់ជាទុក្ខ **លោភៈជាហេតុនាំមកនូវសេចក្តីទុក្ខ** ត្រូវការប្រាថ្នាវត្ថុណាហើយមិនបានក៏ជាទុក្ខ ប៉ងថាវត្ថុនោះនឹងជាយ៉ាងនោះ តែវត្ថុនោះក៏មិនទៅជាយ៉ាងនោះ ដូចដែលប៉ងទុកក៏ជា

ទុក្ខ **ការល្អជាទីបំផុតគឺមិនប៉ងប្រាថ្នា** ព្រោះគ្រប់សភាវៈដែលមានហេតុបច្ច័យក៏នឹងត្រូវកើតរួចហើយ មិនថាប៉ងក្ដីមិនប៉ងក្ដី សូម្បីត្រឹមតែការប៉ងក៏ជាទុក្ខហើយ ដូច្នោះ **បើមិនចង់ទុក្ខ ក៏កុំប៉ងប្រាថ្នា** ។ កើតមកដើម្បីធ្វើនាទីគ្រប់យ៉ាងឱ្យល្អជាទីបំផុត **មិនប៉ងប្រាថ្នាអ្វីមកជំនួសឡើយ ពីសភាវៈដែលធ្វើរួចទៅហើយនោះ** បើកើតផលល្អក្ដី ក៏មិនមានប៉ងប្រាថ្នាថានឹងត្រូវការល្អដល់ថ្នាក់នេះថ្នាក់នោះដែរ កាលធ្វើល្អទីបំផុតហើយក៏សប្បាយចិត្ត ព្រោះមិនចាំបាច់ក្ដៅក្រហាយថា ធ្វើមិនសូវជាល្អសោះ ដូច្នោះទើបធ្វើគ្រប់យ៉ាងឱ្យល្អដល់ទីបំផុត ដើម្បីការពារនូវសេចក្ដីក្ដៅរោលរាលចិត្ត។ កាលធ្វើល្អទីបំផុតហើយ អ្វីនឹងកើតក៏កើត បើសិនល្អក៏ល្អ បើមិនល្អក៏ជួយមិនបាន **ហើយក៏មិនបានត្រូវការឱ្យនរណាមកសរសើរផងដែរ** ព្រោះបើសិនធ្វើដោយប្រាថ្នាឱ្យគេសរសើរ ក៏នឹងជាទុក្ខទៀត ហើយថាឧស្សាហ៍ធ្វើស្ទើរស្លាប់មិនឃើញ មាននរណាសរសើរសោះ ក្លាយទៅជាថាធ្វើល្អដើម្បីត្រូវការឱ្យគេសរសើរវិញ **ដូច្នោះនឹងត្រូវមិនញាប់ញ័រនឹងពាក្យសរសើរ ឬពាក្យនិន្ទា** ។ ធ្វើយ៉ាងល្អទីបំផុតហើយ មិនប្រាថ្នាឡើយថាអ្វីនឹងកើតមិនត្រូវទទួលខុសត្រូវក្នុងលោក ដូចអ្នកដែលមានបងប្អូនច្រើនគ្នា ក៏មិនត្រូវមកអង្គុយគិតថា ពុកម៉ែស្រឡាញ់យើងឬទេ ? ស្រឡាញ់យើងខ្លាំងដូចបងប្អូនដទៃឬទេ ? ទោះជាពុកម៉ែមិនស្រឡាញ់យើងក៏ដោយ តែយើងស្រឡាញ់ពុកម៉ែ យើងក៏សប្បាយចិត្ត ។ ក្រៅពីឪពុកម្ដាយហើយក៏នៅមានដល់មិត្តភក្ដិទៀត ទោះជានរណានឹងស្រឡាញ់យើង

ឬមិនស្រឡាញ់យើង ក៏ជារឿងរបស់គេ យើងមិនយកចិត្តទុកដាក់ ប៉ុន្តែយើងនៅតែជាមិត្តនឹងគេ ហើយប្រាថ្នាល្អដល់គេ យើងក៏សប្បាយចិត្ត ។ យើងមិនកង្វល់ចំពោះសេចក្តីមិនល្អរបស់អ្នកដទៃ ប៉ុន្តែយើងមាននាទីនឹងពង្រីកកែខៃចម្រើនបញ្ញារបស់យើងខ្លួនឯង ហើយនៅជួយអ្នកដទៃបានផង ការប្រព្រឹត្តរបស់យើង ដោយពាក្យនិយាយរបស់យើង ដោយគំនិតរបស់យើង គឺយើងមិនជាភ័យនឹងនរណាឡើយ ។ ពេលនរណាក្រោធសូម្បីបន្តិចបន្តួចយើងដឹងភ្លាមថា គេកើតទុក្ខ ពេលនរណាមិនចូលចិត្តនឹងអ្នកណាមួយបន្តិចៗក្តី យើងក៏ដឹងថាគេកំពុងមានសេចក្តីទុក្ខពិតប្រាកដណាស់ ពីការមិនចូលចិត្តខណៈនោះ ។ **គ្រប់យ៉ាងមិនទៀង ហើយយើងក៏នឹងរស់នៅក្នុងលោកនេះមិនបានយូរទៀតដែរ ព្រោះដូច្នោះរវាងការមានជីវិតរស់នៅ ក៏ធ្វើនូវសភាពដែលជាប្រយោជន៍ទាំងសងខាង គឺមិនយកសេចក្តីទុក្ខទៅឱ្យអ្នកណាហើយនឹង មិនយកសេចក្តីទុក្ខមកឱ្យដល់ខ្លួនយើងដែរ ។** ទម្រាំនឹងយើងកើតជាមនុស្សនេះ យើងសន្សំមកប៉ុន្មានជាតិហើយ សូម្បីតែការអង្គុយ ការដេក ការឈរ ការដើររបស់មនុស្សម្នាក់ៗក៏ត្រូវសន្សំមកដែលក្នុងជាតិនេះក៏សន្សំមកតាំងពីក្មេងដែរ ។

កាលណាកម្មដែលនឹងឱ្យផលក្នុងជាតិនេះនៅមាន ក៏ញ៉ាំងសេចក្តីស្លាប់មិនបាន ដល់ថ្នាក់ធ្វើឱ្យជាយ៉ាងណាក៏ស្លាប់មិនបានដែរ ។ ដោយច្រើននោះ ទុក្ខផ្លូវចិត្តកើតបន្តពីទុក្ខផ្លូវកាយ វេលាឈឺចុកចាប់មិនស្រួលក៏

ព្រួយបារម្ភកង្វល់ សេចក្តីឈឺចុកចាប់នោះប្រៀបដូចជាការត្រូវចាក់ដោយផ្លែកូនសរទី ១ ប៉ុន្តែសេចក្តីទុក្ខផ្លូវចិត្ត សេចក្តីព្រួយ សេចក្តីបារម្ភកង្វល់ ប្រៀបដូចជាផ្លែកូនសរទី ២ ដែលចាក់ចំដដែលទៀតត្រង់មុខរបួសចាស់ របួសក៏រហែកកាន់តែខ្លាំងឡើង ហើយនឹងទុក្ខរោលរាលខ្លោចផ្សាកើនឡើងទៀតប៉ុណ្ណាទៅ ទុក្ខផ្លូវកាយនោះគេចមិនផុតទេ ព្រោះមានកាយក៏ត្រូវមានទុក្ខ មូសខាំឈឺ កាលបើមិនខឹងសម្បាទេ ផ្លែកូនសរទី ២ ក៏មិនមាន គឺមានតែផ្លែទី ១ ប៉ុណ្ណោះ ។

កាលណាប្រៀបនូវសេចក្តីព្រួយបារម្ភ សេចក្តីកង្វល់ ជាផ្លែកូនសរទី ២ ក៏នឹងឃើញច្បាស់ថា មិនគួរនឹងឱ្យត្រូវចាក់ដោយផ្លែកូនសរទី ២ ដដែលទៀតឡើយ ទុក្ខផ្លូវកាយកើតឡើងក៏មើលថែទាំព្យាបាលទៅ មិនត្រូវទៅជាព្រួយបារម្ភកង្វល់កើនឡើងទៀត សេចក្តីកង្វល់មិនមានប្រយោជន៍អ្វីទាល់តែសោះ ជារឿងវែងដែលគ្មានសារៈ ដែលមិនអាចធ្វើឱ្យអ្វីបានល្អឡើយ កាលណាឈឺចុកចាប់ ក៏មើលថែរក្សាទៅនឹងអស់ពេលដោយការព្រួយបារម្ភកង្វល់ ឱ្យជាទុក្ខក្តៅក្រហាយធ្វើអ្វី ។

វេលាយើងសុខក៏ដឹងថា សេចក្តីដឹងខ្លួនសុខជាយ៉ាងណា វេលាអ្នកដទៃជាសុខក៏សុខយ៉ាងនោះដែរ វេលាយើងក្រោធ សេចក្តីដឹងខ្លួនជាយ៉ាងណា អ្នកដទៃក្រោធក៏ដឹងខ្លួនយ៉ាងនោះដែរ សេចក្តីស្រឡាញ់ សេចក្តីស្អប់របស់មនុស្សក៏ដូចៗគ្នាទាំងអស់ ។ **បើយកឈ្មោះនៃគ្រប់**

**មនុស្សចេញអស់ក៏មានតែសភាវធម៌ដែលកើតឡើងហើយរលត់ទៅ ជាធាតុតែមួយបែបៗ** ចិត្តក៏ជាធាតុមួយបែប ។ យើងរៀនរឿងធាតុច្រើនយ៉ាង ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ប៉ុន្តែចិត្តជាធាតុពិសេសដែលជាធាតុដឹង និងជាធាតុដែលវិចិត្រហួសប្រមាណ ។ គំនិតរបស់មនុស្សបែកខ្ញែងចេញទៅមិនមានថ្ងៃចប់ ព្រោះចិត្តជាធាតុខាងដឹង ខាងគិត ទើបមិនមែនងាយនឹងស្គាល់ចិត្តរបស់យើងឡើយ ។ លុះត្រាតែបានស្តាប់នូវព្រះធម៌ច្រើនឡើង និងពិចារណារហូតដល់ចិត្តរបស់យើងបើកផ្សាយចេញមកឱ្យដឹងសេចក្តីពិតប្រាកដនៃចិត្តសន្តានបាន មិនមែនមើលតែការធ្វើការប្រព្រឹត្តម្យ៉ាងប៉ុណ្ណោះទេ ដូច្នោះទើបមានសតិថ្នាក់មួយទៀត គឺខណៈរលឹកដឹងនូវសភាពចិត្តសន្តានរបស់ខ្លួនឯង ប៉ុន្តែនឹងត្រូវជាបុគ្គលត្រង់ទើបនឹងដឹងបាន **អ្នកដែលនឹងសិក្សាធម៌ពិតៗនោះត្រូវជាអ្នកត្រង់** ត្រូវត្រង់ពិតៗទើបនឹងមិនលំអៀង គឺមិនចូលខាងខ្លួនឯង ។ **ធម៌ត្រូវជាធម៌តាមសេចក្តីពិត** ដូចការឱ្យ ការឱ្យទានពិតៗនោះមិនមែនឱ្យដើម្បីប៉ងប្រាថ្នាថាថ្ងៃក្រោយគេនឹងឱ្យវិញទេ ការឱ្យទាននោះត្រូវជាចិត្តសន្តានដែលស្អាតប្រាសចាកអកុសល ។

ចិត្តកើតរលត់រហ័សណាស់ ម្តងជាអកុសល ម្តងជាកុសល មិនមែនថានឹងជាកុសលរហូត ឬមិនមែនថានឹងជាអកុសលរហូតរាល់ពេលនោះទេ ។ "កុសល" ជាសភាវធម៌ដែលល្អស្អាត ជាហេតុឱ្យកើតផលល្អ "អកុសល" ជាសភាវធម៌ដែលមិនល្អ ជាទោស ជាហេតុឱ្យកើតផលមិន

ល្អ ។ កាលណាមិនស្ដាប់ព្រះធម៌ ក៏មិនដឹងសេចក្ដីពិតរបស់សភាវធម៌ ឯការដឹងគឺបញ្ញាក៏មានច្រើនលំដាប់ថ្នាក់ ការដឹងថ្នាក់បានឮ បានស្ដាប់ព្រះធម៌ ជាការដឹងថ្នាក់ដែលមិនអាចរំលត់នូវការយល់ខុស និងអកុសលទាំងឡាយបានឡើយ គឺគ្រាន់តែជាការដឹងថ្នាក់លះបង់ការមិនដឹងពីការមិនដែលធ្លាប់បានឮ បានស្ដាប់ប៉ុណ្ណោះ ។

រឿងសេចក្ដីក្រោធ និងសេចក្ដីមិនក្រោធនោះ បើសន្សំបញ្ញាមកក៏នឹងដឹងថា " មិនក្រោធល្អជាង " តែបើមិនបានសន្សំបញ្ញាមក ក៏គិតថាត្រូវតែក្រោធ ត្រូវតែតបត ទោះនឹងឱ្យគិតដល់ប៉ុណ្ណា ក៏គិតមិនចេញថាមិនក្រោធល្អជាងក្រោធបានឡើយ ដូច្នោះទើបត្រូវពិចារណាឱ្យឃើញទោសរបស់អកុសល និងឃើញប្រយោជន៍របស់កុសល ហើយអប់រំចម្រើនកុសលឱ្យកើនឡើង ។ ល្បងមើលអ្នកដែលយើងស្គាល់ អ្នកខ្លះចិត្តល្អអើពើ ជួយសង្គ្រោះបុគ្គលនេះខ្លះ នោះខ្លះ មិននិយាយអាក្រក់ពីនរណា ហើយធ្វើបុគ្គលដែលយល់ខុសនឹងគ្នាឱ្យយោគយល់គ្នា និងសាមគ្គីគ្នាបាន មានការប្រព្រឹត្តដែលជាកុសលសីល គឺការប្រព្រឹត្តសភាពដែលជាប្រយោជន៍ តាមផ្លូវកាយ តាមផ្លូវវាចា ប៉ុន្តែបុគ្គលខ្លះទៀតក៏ផ្ទុយអំពីនេះ មានតែរឿងច្រណែន រឿងក្រោធ នឹកដល់តែការមិនល្អផ្សេងៗ មានការប្រព្រឹត្តផ្លូវកាយ ផ្លូវវាចាមិនគួរ មិនសមរម្យ ធ្វើឱ្យអ្នកដទៃក្ដៅក្រហាយ ។ ពាក្យនិយាយដែលមិនគិតដល់អ្នកស្ដាប់ ប្រសិនបើយើងជា

អ្នកស្ដាប់វិញក៏នឹងដឹងខ្លួនថា មិនសមគួរស្ដាប់ពាក្យយ៉ាងនេះ ប៉ុន្ដែកាលជាអ្នកនិយាយក៏ភ្លេចគិត ថែមទាំងមិនដឹងថា ខណៈនោះក៏ជាអកុសល ។

" ទាន " ការឱ្យនោះកើតឡើងជាមួយដងមួយកាល តែចំពោះអ្នកកំណាញ់ស្វិតក៏លំបាកនឹងឱ្យបាន ។ ចិត្តឱ្យទានជាកុសល ជាចិត្តដែលល្អស្អាត ជាបច្ច័យឱ្យកើតកុសលវិបាកគឺផលល្អ ព្រះមានព្រះភាគព្រះអង្គទ្រង់ត្រាស់ទុកក្នុងព្រះសូត្រថា " បើអ្នកណាដឹងផលនៃទាន ដូចតថាគតដឹងហើយយ៉ាងនោះ អ្នកនោះតែងមិនបរិភោគមុនការឱ្យទានឡើយ " ដូចបុគ្គលក្នុងផ្ទះយើងដែលរស់នៅជាមួយគ្នា គ្រប់បុគ្គលតែងចូលចិត្តអាហាររសឆ្ងាញ់ បើយើងមានអាហាររសឆ្ងាញ់ ហើយយើងបរិភោគតែម្នាក់ឯងដឹងខ្លួនដូចជាជាប់កលេបមិនរួច ព្រោះដឹងថាបុគ្គលដទៃក៏ចង់ហូប ចង់ភ្លក់អាហារឆ្ងាញ់ៗផងដែរ ។ ដូច្នោះបើចែកឱ្យគេ ត្រូវចែកពីដំបូង គឺសុខចិត្តទាំងយើងទាំងគេ មិនមែនទុកដាក់អស់ច្រើនថ្ងៃស្ទើរតែនឹងខូចហើយយកមកឱ្យគេនោះទេ ព្រោះថាមុខជាយើងនឹងឱ្យដដែល គឺឱ្យតាំងតែនៅមានរសឆ្ងាញ់ល្អ ជាជាងឱ្យកាលសេសសល់ហើយ ឬក៏កាលចាស់ហើយនោះ គួរគិតដល់សេចក្ដីដឹងខ្លួនបញ្ច្រាសវិញ គឺបើយើងជាអ្នកទទួល ពេលដែលបានទទួលវត្ថុដែលល្អ ក៏ដឹងខ្លួនជាសុខសោមនស្សយ៉ាងណា អ្នកដទៃក៏យ៉ាងនោះដែរ ។

ការឱ្យទានជាសភាវៈដែលល្អស្អាត ជាកុសល ព្រោះខណៈឱ្យទាន នោះចិត្តទន់ភ្លន់ បើអ្នកទទួលជាអ្នកដែលមិនធ្លាប់ចូលចិត្តយើង ឬជាសត្រូវនឹងយើង កាលបានទទួលវត្ថុដែលមកពីមេត្រីចិត្តរបស់យើង គេក៏រមែងនឹងកើតសេចក្តីដឹងខ្លួន ដែលទន់ភ្លន់ និងមានភាពជាមិត្តផងដែរ សូម្បីថាយើងមិនប្រាថ្នាផល ថានឹងឱ្យគេស្រឡាញ់យើងក៏ដោយ ប៉ុន្តែគឺដឹងថា ការឱ្យទានជាផ្លូវនឹងធ្វើឱ្យចិត្តបុគ្គលទន់ចុះ និងកើតកុសលបាន ។ គ្រាន់តែពាក្យនិយាយពីរោះពិសា ដែលកើតពីកុសលចិត្តក៏ធ្វើឱ្យអ្នកស្តាប់សប្បាយចិត្ត ទាំងចិត្តនៃអ្នកនិយាយខណៈនោះក៏ទន់ភ្លន់ដែរ ភាពជាបុគ្គលទន់ភ្លន់ ឱនលំទោននោះធ្វើឱ្យលះបង់នូវសេចក្តីប្រកាន់ខ្លួន ការទម្រើសខ្លួន ឬការអួតខ្លួនដែលជាការមិនល្អឡើយ ហើយកុសលនោះក៏មិនមែនមានតែទានមួយយ៉ាងនោះដែរ ទានជាកុសលថ្នាក់ដើម ។ បើយើងឱ្យគេ ហើយបៀតបៀនគេ ដោយប្រើវាចាធ្វើឱ្យគេអន់ចិត្ត គេក៏មិនចង់បានវត្ថុដែលយើងឱ្យដែរ ឬអាចឱ្យរកាំចិត្តលើសជាងការទទួលវត្ថុយើងឱ្យទៅទៀត បើយើងឱ្យដោយកិរិយាមិនសមគួរ ឬដោយវាចាដែលធ្វើឱ្យអ្នកទទួលមិនចង់នឹងបាន ក៏ទុកដូចជាការឱ្យទៅដោយសេចក្តីមើលងាយ ឱ្យទៅដោយសេចក្តីមិនពេញចិត្ត ។ ដូច្នោះសូម្បីក្នុងការឱ្យដល់អ្នកសុំទានក៏ដោយ បើជាអ្នកស្គាល់កុសលចិត្ត ក៏នឹងឱ្យដោយកិរិយាមិនមែនបោះបោក ប្រាកដជាដាក់ឱ្យយ៉ាងល្អ ដោយរីករាយជ្រះថ្លា ហើយអាច

មានពាក្យពោល ឬកិរិយាអាការៈធ្វើឱ្យគេសប្បាយចិត្តផងដែរ ដោយមិនមានកាយវាចាបង្ហាញការមើលងាយមើលថោកអ្វីទាំងអស់ ។

〝 សីល 〞 គឺការប្រព្រឹត្តតាមផ្លូវកាយ ផ្លូវវាចាមាន ៣ យ៉ាងគឺ : ការវៀរនូវទុច្ចរិត ១ ការគោរពដល់អ្នកដែលគួរគោរព ១ ការជួយសង្គ្រោះដល់អ្នកដទៃ ១ ។ ប៉ុន្តែថាទាំងអស់នោះដែលមានការឱ្យទានក្តី មានសីលក្តី និងការជួយសង្គ្រោះអ្នកដទៃក្តី ចិត្តក៏នៅតែក្រហល់ក្រហាយជាទុក្ខដូច្នោះទើបមានកុសលថ្នាក់មួយទៀត គឺមានបញ្ញាឃើញទោសរបស់អកុសលចិត្ត សូម្បីថាមិនទាន់មានការប្រព្រឹត្តនូវទុច្ចរិតតាមកាយ តាមវាចាណាៗក៏ដោយ ប៉ុន្តែចិត្តក៏ជាទុក្ខក្តៅក្រហាយ ព្រោះអកុសលដែរទើបត្រូវតែសន្សំអប់រំបញ្ញាឱ្យឃើញទោសរបស់អកុសលពិតៗ ។ ព្រះធម៌ដែលបានស្តាប់ និងបានពិចារណា ហើយរមែងសន្សំនៅក្នុងសន្តានចិត្តធ្វើឱ្យពិចារណាដឹងថា មុននឹងដេកលក់ តើចិត្តជាកុសល ឬជាអកុសលមុននឹងលក់នោះតើគិតអ្វី បើសិនជាគិតរឿងលោភៈ ប្រាកដជាគ្មានថ្ងៃចប់សោះឡើយ បើសិនគិតរឿងទោស ក៏ប្រាកដជាមួម៉ៅ គឺមួម៉ៅមុនរួចស្រេចទៅហើយ ដែលសភាពរឿងនោះពុំទាន់មកដល់ផង ប៉ុន្តែបើសិនគិតក្នុងរឿងល្អថានឹងធ្វើអ្វីខ្លះដែលជាប្រយោជន៍ដល់អ្នកដទៃ ចិត្តក៏សប្បាយ ។

សេចក្តីក្រោធនឹងបន្ថយចុះបានដោយសារអ្វី គឺដោយសារធម៌ដែលប្រឆាំងទំនាស់នឹងសេចក្តីក្រោធ គឺមេត្តា សេចក្តីជាមិត្ត សេចក្តីប្រាថ្នាល្អ

សេចក្ដីផ្គត់ផ្គង់ ។ ពាក្យថា " មេត្តា " នោះជាភាសាខ្មែរ បើពាក្យថា "មិត្ត" គឺសំឡាញ់ ។ ពាក្យថាសំឡាញ់នោះស៊ីជម្រៅទៅដល់សេចក្ដីមិនប្រាថ្នាអាក្រក់ដល់អ្នកដែលយើងជាសំឡាញ់ជាមួយ ។ កាលណាយើងជាសំឡាញ់នឹងនរណា យើងកុំប្រណាំងប្រជែង ឬកុំគិតនឹងប្រណាំងប្រជែងនឹងអ្នកនោះ បើគិតប្រណាំងប្រជែងជាមួយនឹងនរណា ខណៈណា ខណៈនោះមិនមានសេចក្ដីថាជាសំឡាញ់នឹងអ្នកនោះដែរ ព្រោះសំឡាញ់ត្រូវទំនុកបម្រុង លើកស្ទួយ ផ្គត់ផ្គង់គ្នារៀងរហូត ។ ពិចារណាដឹងបានថាចិត្តខណៈណាជាសំឡាញ់នឹងនរណា ដូចជាវេលាទទួលទានអាហារជាមួយគ្នាក៏ជាសំឡាញ់ ប៉ុន្តែដល់ម៉ោងធ្វើការក៏មិនមែនជាសំឡាញ់អស់ជាសំឡាញ់ហើយក៏អាចបាន ។

**បដិបត្តិធម៌ក្នុងជីវិតប្រចាំថ្ងៃ គឺអប់រំចម្រើនកុសលឱ្យកើនច្រើនឡើង ។**

បុគ្គលម្នាក់ៗត្រូវការសុខស្អប់ទុក្ខ មានលោភៈ ទោសៈ មោហៈ ដូចគ្នា ប៉ុន្តែនរណាមានសទ្ធាស្ដាប់ព្រះធម៌ នរណាអប់រំចិត្តសន្ដានឱ្យឡើងខ្ពស់សឹងជាផ្លូវដែលទៅផុតចាកសេចក្ដីទុក្ខ ដែលកើតពីកិលេស ព្រោះបុគ្គលដែលមានកិលេសនោះជាទុក្ខ ខណៈណាជាទុក្ខ ក៏ដឹងបានថាព្រោះមានកិលេស ។ ទុក្ខច្រើនក៏ព្រោះមានកិលេសច្រើន ទុក្ខតិចក៏ព្រោះមានកិលេសតិច និងមិនមានទុក្ខសោះ ក៏ត្រូវរំលត់កិលេសឱ្យអស់ ។

ពេលអ្នកដទៃធ្វើកុសល តើយើងត្រេកអរនឹងគេឬទេ អនុមោទនាក្នុងកុសលចិត្តរបស់គេឬទេ ឬក៏ព្រងើយៗទេ បើយើងព្រងើយៗមិនអនុមោទនា កាលស្លាប់ទៅហើយនរណាធ្វើកុសល ក៏នៅតែព្រងើយៗមិនអនុមោទនាដែរ ក៏ដូចនឹងជាតិនេះ ដែលមិនអនុមោទនាយ៉ាងនោះឯង ប៉ុន្តែបើជាតិនេះឃើញនរណាធ្វើល្អក៏ត្រេកអរជាមួយ អនុមោទនាជាមួយ កាលស្លាប់ទៅហើយដឹងថានរណាធ្វើល្អ ក៏អនុមោទនា ។ ចិត្តរបស់អ្នកដែលអនុមោទនាជាកុសលចិត្ត មិនមែនបុគ្គលដទៃអាចយកកុសលទៅឱ្យបាននោះទេ ។

អ្នកណាអនុមោទនា ចិត្តរបស់អ្នកនោះជាកុសលដូចប្រហែលនឹងជាតិនេះ ខណៈនេះដែរ គ្រាន់តែថាជាតិមុខនោះជាភពភូមិមើលមិនឃើញផ្ទាល់ ក៏ស្រេចតែថា តើនឹងកើតត្រង់ភពភូមិណា បើកើតជាប្រេតឬទេវតា ដឹងបានក៏អាចអនុមោទនាបាន ប៉ុន្តែក៏ត្រូវអាស្រ័យជាមួយដែលថា នឹងកើតកុសលចិត្តអនុមោទនា ឬមិនកើត ។

**<u>កំណត់ហេតុ</u>**៖ បើសិនសេចក្តីនេះជាហេតុបច្ច័យឱ្យកើតកុសលសូមឧទ្ទិសចំណែកកុសលឱ្យ ម.ល.ទ័យក្បេម ស្និទ្ធវង្ស និង អ្នកមានចិត្តសោមនស្សត្រេកអរអនុមោទនាក្នុងចំណែកកុសលនេះផងចុះ ។

# ដាស់តឿនចិត្ត

បុគ្គលដែលមានពេលទំនេរច្រើន ច្រើនចំណូលចូលចិត្តគិតតែសេចក្តីមិនល្អពីអ្នកដទៃ ។

ជម្លោះ ការវិវាទ សេចក្តីរីងរៃសោកសៅដែលកើតពីសត្វ និងសង្ខារដ៏ជាទីស្រឡាញ់ មានព្រមជាមួយនឹងការកំណាញ់ ការស្តាយ ការឃើញតែពីខាងខ្លួន ។

ទុក្ខព្រោះសេចក្តីស្រឡាញ់ ឈ្មោះថាទុក្ខនេះមានវត្ថុដែលជាទីស្រឡាញ់ជាហេតុ វត្ថុដែលជាទីស្រឡាញ់មានប្រមាណប៉ុណ្ណា ទុក្ខក៏មានប្រមាណត្រឹមប៉ុណ្ណោះ ។

សេចក្តីស្រឡាញ់ក្នុងស្វាមី ភរិយា បុត្ត និងញាតិ ហាក់ដូចជាគុម្ពឬស្សីមានបន្លាក្រាស់ ច្រង៉េងច្រង៉ាងពពាក់ពពូន ចាក់ស្រេះគ្នាយ៉ាងណាតណ្ហា រាគៈ សរាគៈ សេចក្តីពេញចិត្ត សេចក្តីត្រេកអរ ការត្រេកត្រអាលចំណង់ដោយអំណាច ការភ្លើតភ្លើន ចំណង់នៃចិត្ត សេចក្តីប្រាថ្នា សេចក្តីវង្វេង ការជាប់ជំពាក់ ការលិចចុះ សេចក្តីញាប់ញ័រ ការបោកប្រាស់ តណ្ហាដែលឱ្យសត្វកើត តណ្ហាដែលឱ្យប្រកបក្នុងទុក្ខ ដោតក្រងទុក តណ្ហាដូចជាសំណាញ់ តណ្ហាដូចទន្លេគង្គា តណ្ហាដោតជាប់ក្នុងអារម្មណ៍ផ្សេងៗសេចក្តីស្រឡាញ់ សេចក្តីស្និទ្ធស្នាល ការសម្លឹង ការពាក់ព័ន្ធ ការសង្ឃឹម

កិរិយាដែលសង្ឃឹម ភាពជាអ្នកប្រាថ្នាក្នុងលាភទ្រព្យ បុត្ត ជីវិត ការចំណូលចូលចិត្ត សេចក្ដីលោភខ្លាំង ការលោភលន់ជាកិលេសដែលប្រកាន់មាំ ដែលរារាំងបាំងបិទ ចងជាប់ទុកក្នុងសេចក្ដីមួហ្មង ។ សេចក្ដីប្រាថ្នាផ្សេងៗនោះ គឺសេចក្ដីស្រឡាញ់ គឺជាអន្ទាក់មារជាសន្ទូចមារជាអំណាចមារ ពង្វក់ជីវិតភ្លេចនូវសេចក្ដីស្លាប់ ។

សេចក្ដីស្រឡាញ់កាលខុសបំណងប្រាថ្នាហើយ និងសូម្បីមិនខុសដល់សីលធម៌ក៏ដោយ ក៏ធ្វើឱ្យកើតនូវការស្អប់ខ្ពើម ចងអាឃាតព្យាបាទដល់ថ្នាក់អាចសម្លាប់ឱ្យស្លាប់ទៅបាន បើស្រាលល្មម ធ្វើឱ្យកើតនូវការប្រច័ណ្ឌព្រួយបារម្ភ ទោសៈ ។ កាលបើមិនបានដូចប្រាថ្នា ក៏ចងអាឃាតគុំគួន តូចចិត្ត អន់ចិត្ត ស្ដាយស្រណោះ ឥច្ឆាប្រស្យា កាប់ចាក់ រោលរាលបំផ្លិចបំផ្លាញ តាមដែលអកុសលចេតនាតាក់តែងទៅផ្សេងៗ ។ ក្ដៅចិត្តខ្វល់ខ្វាយចិត្ត គិតបំផ្លាញ គិតធ្វើអាក្រក់ដល់អ្នកដទៃ និងដល់ខ្លួនឯងគឺដោយប្រកាន់សិទ្ធិថា ជាថៅហ្វាយចំពោះខ្លួន កាលណាស្រឡាញ់ខ្លាំងហើយ ខុសបំណងប្រាថ្នា ក៏មានទុក្ខខ្លាំង ។

សេចក្ដីខូចចិត្ត តូចចិត្តអណ្ដើតអណ្ដក់ គឺបំផ្លាញសុខភាពរាងកាយធ្វើឱ្យល្ងើល្ងើបាត់សតិ មិនមានបញ្ញា កែបញ្ហាមិនបាន ធ្វើឱ្យបាត់នូវការចម្រើនលូតលាស់ គិតតែពីសេចក្ដីច្រងើងច្រង៉ាង និងទំនួញទួញយំយែកគិតតែពីសេចក្ដីល្អរបស់ខ្លួន និងតែពីសេចក្ដីមិនល្អរបស់អ្នកដទៃជានិច្ច

កាលតែប៉ុណ្ណោះ ។ សេចក្ដីស្រឡាញ់ធ្វើឱ្យឃើញតែពីខាងខ្លួន បង្កើតការក្ដៅក្រហាយដល់អ្នកដទៃដែលបានឃើញ បានជួបចងគំនុំបុគ្គលដែលមកទាក់ទងទំនាក់ទំនងនឹងអ្នកដែលស្រឡាញ់ កើតចិត្តវិបរិត បង្កើតសេចក្ដីវិបល្លាស ព្រោះពាក្យសំដីធ្វើឱ្យចិត្តឈឺផ្សា ធ្វើឱ្យកើតភាពភ័យខ្លាច បោកបញ្ឆោតដែលទាក់ទងនឹងអ្នកដទៃផ្សេងៗ យកខុសធ្វើជាត្រូវ យកត្រូវធ្វើជាខុស ។

ចិត្តមានបំណងថោកទាបគិតធ្វើអាក្រក់ខ្លួនឯង និងអ្នកដទៃរមែងពោលនូវវាចាមិនសុភាពជានិច្ច រង់ចាំទទួលតែទារុណនៃចិត្ត (កិលេសរបស់ខ្លួនឯង) ក្នុងពេលនៅរួមរស់ជាមួយគ្នា កាលណាត្រូវកុហកបញ្ឆោតបោកប្រាស់ផ្សេងៗ ។

ភ័យនៃសេចក្ដីស្រឡាញ់ដោយតណ្ហាមាន ៖ សេចក្ដីចូលចិត្តសេចក្ដីស្និទ្ធស្នាល ចិត្តពាក់ព័ន្ធក្នុងស្វាមី ភរិយា បុត្ត និងញាតិមិត្ត អ្នកបម្រើសត្វផ្សេងៗ ស្រែចម្ការ ផ្ទះសំបែង ដីធ្លី ដោយប្រកាន់ថាជារបស់យើង ទើបកើតជាជម្លោះ ការប្រឆាំង ការដណ្ដើម អាចហ៊ានប្រព្រឹត្តនូវទុច្ចរិតតាមកាយ វាចា ចិត្ត ខុសសីលបានគ្រប់ចំណុច មានអគតិផ្សេងៗធ្វើទារុណដល់អ្នកដទៃផ្សេងៗ ធ្វើកម្មដ៏លាមកផ្សេងៗ សងសឹក ឬបោះបញ្ឆោះ ដោយធ្វើសភាពដែលនឹងធ្វើឱ្យខ្លួនឯងកាចអាក្រក់ផ្សេងៗ បោកកញ្ជ្រោក ឡូឡា កាលមិនបានដូចសេចក្ដីប្រាថ្នា ។ កាលណាមិនសម

តាមបំណងក្នុងការស្រឡាញ់ ក៏សំដែងអាការៈគួរខ្ពើមគួរខ្លាច មុខមាត់ក្រហម គ្មានខ្លាចអ្វីឡើយ តាមកម្លាំងរបស់កិលេសដែលបុគ្គលម្នាក់ៗសន្សំទុកមក ។

ទំនួញទួញត្អូញត្អែរ រវើរវាយដោយសេចក្ដីទុក្ខសោកញាំញីនោះមានតិចមានច្រើនតាមសេចក្ដីផ្សេងៗគ្នានៃនិស្ស័យ ។ សេចក្ដីសោយសោកកើតព្រោះអារម្មណ៍ដ៏ជាទីស្រឡាញ់នោះៗ ។

កាលណាឃើញទោសភ័យនៃសេចក្ដីស្រឡាញ់ហើយ ក៏គួរមានមេត្តា សេចក្ដីជាមិត្ត ឧបការៈអើពើ ជ្រោមជ្រែង ផ្គត់ផ្គង់ ប្រាថ្នាល្អដល់គ្នានិងគ្នា ។

យើងមិនត្រូវប្រទូសរ៉ាយឡើយ សូម្បីជាសត្រូវរបស់យើង និងជាអ្នកមានបំណងអាក្រក់ដល់យើងក៏ដោយ អ្នកណាមានបំណងអាក្រក់នោះក៏ជាអកុសលរបស់គេ មិនមែនរបស់យើង ។ អ្នកមិនទទួលសេចក្ដីអាក្រក់របស់អ្នកដទៃ គឺអ្នកឈ្នះកិលេសរបស់ខ្លួនឯងបាន រមែងទទួលនូវសភាវធម៌គ្រប់យ៉ាង ព្រមជាមួយនឹងឱ្យអភ័យបានជានិច្ច ក៏នឹងមានតែសេចក្ដីសុខប៉ុណ្ណោះ ។

ចូរអត់ធន់នឹងសេចក្ដីអាក្រក់កំណាចឃោរឃៅ របស់អ្នកដទៃដោយសេចក្ដីរីករាយ មានមេត្តាចំពោះអ្នកនោះ រលឹកដល់សេចក្ដីល្អរបស់

អ្នកនោះដែលគេមានខ្លះ ឱ្យអភ័យ និងអាណិតដែលគេនោះឯងនឹងបានទទួលផលកម្មដែលគេបានធ្វើ ។ សត្វតែងសំដែងសេចក្ដីមិនល្អចេញមកត្រង់ៗ ប៉ុន្តែមនុស្សយើងមានការលាក់កំណួច លាក់អាថ៌កំបាំង ស៊ីជម្រៅក្រៃងពុតត្បុត ធ្វើជាមិនដឹង ចិត្តមិនស្រស់មិនថ្លា តើនរណានឹងដឹង ប៉ុន្តែកាលបើមានសតិ ក៏នឹងដឹងបានថា ជាកិលេសតែខ្លួនឯងប៉ុណ្ណោះ ដឹងបានហើយប្រដៅចិត្តខ្លួនឯង បើមិនដូច្នោះទេ កិលេសនោះក៏នឹងសន្សំជាឧបនិស្ស័យ កាន់តែក្រាស់ឡើងៗ ។

បើជាអ្នកអត់ធន់ និងរម្ងាប់សេចក្ដីក្រោធបានរឿយៗ ដោយការមានសតិ មានមេត្តាដល់អ្នកប្រទូសរ៉ាយ ឬល្មើសជ្រុលជ្រួសដល់លោកអ្នក សម័យខាងក្រោយក៏នឹងជាអ្នកមិនងាយក្រោធដូចបុគ្គលដទៃៗដែរ ។

កុំបង្អាក់សទ្ធា ចូរចម្រើនកុសលរឿយៗមានឱកាសគួរខិតខំចម្រើនកុសលឱ្យទាន់ពេល ព្រោះបន្ទាប់តទៅ អាចអស់ឱកាសបាន ។

កុំខំអន្ទះសារករបស់ដែលបាត់ ជារឿយៗចូររកទីពឹងពំនាក់នូវបុញ្ញកម្មរបស់ខ្លួនឯងឱ្យមាំទាំ កម្មធ្វើឱ្យមានបាន កម្មក៏ធ្វើឱ្យបាត់បង់វិនាសបានដែរ ។

បុណ្យ គឺកុសលកម្មដែលបានធ្វើមកហើយហាក់ដូចជាញាតិដ៏ស្និទ្ធដែលជាប់តាមជួយសង្គ្រោះ ។ បើទុកចិត្តក្នុងកម្មដែលបានធ្វើរួចហើយ

ប្រាកដនឹងធ្វើឱ្យមាំទាំក្នុងការប្រកបតែកុសលកម្មជានិច្ច ។

ខ្យល់ដកដង្ហើម ជាសភាវៈសំខាន់ណាស់ ព្រោះជីវិតទ្រទ្រង់តាំងនៅបានត្រឹមតែមួយជួរខណៈ ដែលនៅមានខ្យល់ដង្ហើមនៅប៉ុណ្ណោះ ។ ការឱបក្រសោបក្នុងជីវិត ក្នុងទ្រព្យសម្បត្តិ ក្នុងរូបសម្បត្តិ ក្នុងវិជ្ជាចំណេះផ្សេងៗ ក្នុងឋានៈក្នុងកិត្តិយស ទាំងអស់នោះក៏អាស្រ័យដោយខ្យល់ដកដង្ហើមដ៏ស្រាលៗ ដែលល្អិតអនេកនោះដែរ ។

គ្រប់សភាវៈក្នុងជីវិត ដែលគិតថាធំដុំឬសំខាន់អនេក សេចក្តីពិតនោះ ក៏គឺអាស្រ័យដោយខ្យល់ដកដង្ហើមដែលជាសភាវៈកើតឡើងត្រឹមតែបន្តិចបន្តួចបំផុត មួយជួរខណៈៗប៉ុណ្ណោះ កាលណាប្រាសចាកខ្យល់ដកដង្ហើមហើយនោះ គ្រប់សភាវៈដែលធ្លាប់ប្រកាន់មកថាជារបស់យើង ក៏អស់រលីង ។ សេចក្តីធំធេង និងសេចក្តីសំខាន់ក្នុងសភាវៈណាៗ ទាំងសេចក្តីស្រឡាញ់ និងទាំងសេចក្តីស្អប់នោះ ក៏ត្រឹមតែជាគំនិតគិតក្នុងខណៈដែលនៅមានខ្យល់ដកដង្ហើមប៉ុណ្ណោះឯង ។

ទីនៅទីអាស្រ័យ គឺទីសម្រាកមួយរយៈ មួយគ្រាក្នុងលោកនេះប៉ុណ្ណោះ មិនគួរកង្វល់ជ្រុលហួសឡើយ ហើយក៏នឹងឃ្លាតប្រាសទៅវិញ។

សូវស្តាយបាន ប្រសើរជាងស្តាយបង់
សូវស្លាប់អង្គ ប្រសើរជាងខូចឈ្មោះ ។
សូវមើលសៀវភៅ ប្រសើរជាងមើលរបាំ
សូវស្តាប់ធម៌ចាំ ប្រសើរជាងស្តាប់ចម្រៀង ។
សូវនិយាយពីធម៌ ប្រសើរជាងនិយាយដៀង
សូវគិតធម៌មិនទៀង ប្រសើរជាងគិតព្យាបាទ ។

បើមើលឃើញចំណេញ កុំភ្លេចរឿងខាត
បើមើលឃើញស្អាត សូមកុំភ្លេចរឿងស្អប់ ។
បើឃើញកំហុស កុំភ្លេចគុណគាប់
ធម្មតាថ្ងៃ និង យប់ ជាគូនឹងគ្នា ។